**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតតំបន់ការពារទេសភាព«រនោមដូនសំ»**

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សម្រេច**

**មាត្រា១.-**

ត្រូវបានបង្កើតតំបន់ការពារទេសភាព «នោមជូនសំ» ដែលមានផ្ទៃដីសរុប ចំនួន ១៤២៣ (មួយពាន់បួនរយម្ភៃបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដូចមាន ផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាគោល (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | |
|---|---|---|---|---|---|
| ID | X | Y | ID | X | Y |
| 1 | 242581 | 1497324 | 21 | 240235 | 1493582 |
| 2 | 242581 | 1496324 | 22 | 240023 | 1493664 |
| 3 | 241844 | 1496324 | 23 | 239524 | 1493673 |
| 4 | 241604 | 1496165 | 24 | 238989 | 1493693 |
| 5 | 241855 | 1495965 | 25 | 238402 | 1493715 |
| 6 | 242072 | 1495969 | 26 | 238691 | 1494087 |
| 7 | 242089 | 1495830 | 27 | 238724 | 1494595 |
| 8 | 241498 | 1495782 | 28 | 238760 | 1494890 |
| 9 | 241414 | 1495462 | 29 | 238394 | 1495134 |
| 10 | 240676 | 1495099 | 30 | 238315 | 1494746 |
| 11 | 240756 | 1494824 | 31 | 238164 | 1494804 |
| 12 | 241286 | 1495088 | 32 | 237863 | 1494725 |
| 13 | 242059 | 1494981 | 33 | 237521 | 1495376 |
| 14 | 242048 | 1494651 | 34 | 237985 | 1495610 |
| 15 | 241961 | 1493943 | 35 | 238449 | 1495661 |
| 16 | 241675 | 1493738 | 36 | 238490 | 1495883 |
| 17 | 241270 | 1493563 | 37 | 238077 | 1495957 |
| 18 | 240889 | 1493269 | 38 | 238732 | 1496313 |
| 19 | 240870 | 1493008 | 39 | 237581 | 1496324 |
| 20 | 240333 | 1493419 | 40 | 237581 | 1497324 |

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា និងការពារសោភ័ណ្ឌភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័ន៌មជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់



www.pheakdeylaw.com

- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌ របស់សហគមន៍មូលដ្ឋាន។

**មាត្រា៣** .-

ផ្ទៃដីនៃអនុក្រឹត្យតំបន់ការពារទេសភាព «រនាមដូនសំ» នេះមិនរួមបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**មាត្រា៤** .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ការពារទេសភាព«រនាមដូនសំ»ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តបន្ទាយមានជ័យ និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីធានាកិច្ចគាំពារ បរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៥** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃទី[illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ កុម្ភៈ ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

# ផែនទី តំបន់ការពារទេសភាព - ទោមជួនសំ - ស្ថិតក្នុងខេត្តបន្ទាយមានជ័យ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៨




និយាមការគោល

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 242581 | 1497324 | 21 | 240235 | 1493582 |
| 2 | 242581 | 1496324 | 22 | 240023 | 1493664 |
| 3 | 241844 | 1496324 | 23 | 239524 | 1493673 |
| 4 | 241604 | 1496165 | 24 | 238989 | 1493693 |
| 5 | 241855 | 1495965 | 25 | 238402 | 1493715 |
| 6 | 242072 | 1495969 | 26 | 238691 | 1494087 |
| 7 | 242089 | 1495830 | 27 | 238724 | 1494595 |
| 8 | 241498 | 1495782 | 28 | 238760 | 1494890 |
| 9 | 241414 | 1495462 | 29 | 238394 | 1495134 |
| 10 | 240676 | 1495099 | 30 | 238315 | 1494746 |
| 11 | 240756 | 1494824 | 31 | 238164 | 1494804 |
| 12 | 241286 | 1495088 | 32 | 237863 | 1494725 |
| 13 | 242059 | 1494981 | 33 | 237521 | 1495376 |
| 14 | 242048 | 1494651 | 34 | 237985 | 1495610 |
| 15 | 241961 | 1493943 | 35 | 238449 | 1495661 |
| 16 | 241675 | 1493738 | 36 | 238490 | 1495883 |
| 17 | 241270 | 1493563 | 37 | 238077 | 1495957 |
| 18 | 240889 | 1493269 | 38 | 238732 | 1496313 |
| 19 | 240870 | 1493008 | 39 | 237581 | 1496324 |
| 20 | 240333 | 1493419 | 40 | 237581 | 1497324 |

សញ្ញាសម្គាល់
- ចំណុចនិយាមកា
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវ
- ព្រំប្រទល់តំបន់ការពារទេសភាពទោមជួនសំ

គម្របព្រៃឈើឆ្នាំ២០១៤
- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ព្រៃដុះឡើងវិញ
- ដីពុំមានគម្របព្រៃឈើ

ផ្ទៃដី តំបន់ការពារទេសភាព - ទោមជួនសំ - សរុប ១៤២៣ ហិកតា

ថ្ងៃទី ២០ ខែ ... ឆ្នាំ២០១៧

សួន ...

សាយ សំអាល់